NSW GOVERNMENT | Health

*បណ្ណព័ត៌មានអំពីជំងឺឆ្លង*

# ជំងឺកញ្រ្ជឹល

***កញ្រ្ជឹលគឺជាជំងឺធ្ងន់ធ្ងរមួយដែលឆ្លងដោយងាយស្រួលតាមរយៈខ្យល់អាកាស។ ការចាក់ថ្នាំបង្ការរោគមានប្រសិទ្ធភាពក្នុងការបង្ការជំងឺនេះ។ កុមារនិងមនុស្សពេញវ័យទាំងអស់ដែលមានកំណើតក្នុងអំឡុង ឬក្រោយឆ្នាំ 1966 គួរចាក់ថ្នាំបង្ការរោគ MMR ចំនួនពីរក៏រិត បើគ្មានប្រព័ន្ធការពារទប់ទល់រោគនេះរួចជាស្រេចទេនោះ។***

## តើជំងឺកញ្រ្ជឹលគឺជាអ្វី?

កញ្រ្ជឹលគឺជាជំងឺបង្កដោយវីរុសដែលអាចមានផលវិបាកធ្ងន់ធ្ងរ។ នៅពេលកន្លងមក ការឆ្លងកញ្រ្ជឹលគឺជាហេតុការណ៍ទូទៅណាស់នៅក្នុងចំណោមកុមារភាព។ ឥឡូវនេះ ជំងឺកញ្រ្ជឹលកំរកើតមានណាស់នៅក្នុងរដ្ឋ NSW ដោយសារតែមានការចាក់ថ្នាំបង្ការរោគនេះ។

## តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

- រោគសញ្ញាដំបូងទាំងឡាយគឺគ្រុនក្តៅ អស់កម្លាំង ក្អក ហៀរសំបោរ ភ្នែកឈឺឡើងក្រហម និងអារម្មណ៍មិនល្អ។ ពីរបីថ្ងៃក្រោយមក កន្ទួលកើតមានឡើង។ កន្ទួលនេះចាប់ផ្តើមនៅលើមុខ ឆ្លងរាលដាលទៅកាន់រាងកាយ និងមានរយៈពេល 4-7 ថ្ងៃ។
- មនុស្សដល់ទៅមួយភាគបីដែលកើតកញ្រ្ជឹលមានផលវិបាក។ ផលវិបាកទាំងនេះមានរួមទាំងការរលាករន្ធត្រចៀក រាករូស និងរលាកសួត ហើយអាចចូលព្យាបាលក្នុងមន្ទីរពេទ្យ។ មនុស្សម្នាក់ក្នុងចំណោមមនុស្ស 1000 នាក់ដែលកើកញ្រ្ជឹលកើតជំងឺរលាកខួរក្បាល (ហើមខួរក្បាល)។

## តើជំងឺនេះឆ្លងតាមវិធីណា?

- ជាធម្មតាកញ្រ្ជឹលចម្លងរាលដាលនៅពេលដែលមនុស្សម្នាក់ដកដង្ហើមចូលនូវវីរុសកញ្រ្ជឹលដែលបានក្អកឬកណ្តាស់ចេញទៅក្នុងអាកាសដោយអ្នកកើតជំងឺនេះ។ កញ្រ្ជឹលគឺជាជំងឺមួយក្នុងចំណោមជំងឺឆ្លងទាំងអស់ដែលងាយឆ្លងបំផុតនៅក្នុងចំណោមមនុស្សយើង។ការគ្រាន់តែស្ថិតនៅក្នុងបន្ទប់ជាមួយនឹងអ្នកកើតកញ្រ្ជឹលក៏អាចបណ្តាលឲ្យឆ្លងជំងឺនេះដែរ។
- ជាធម្មតាអ្នកកើតកញ្រ្ជឹលឆ្លងជំងឺនេះនៅនឹងមុនពេលដែលរោគសញ្ញាចាប់ផ្តើម រហូតដល់ពេលបួនថ្ងៃក្រោយពីកន្ទួលលេចរូបរាងឡើង។ ជាទូទៅរយៈពេលចាប់ពីពេលឆ្លងរោគរហូតដល់ពេលមានជំងឺមានចំនួនប្រហែល 10 ថ្ងៃ។ ជាធម្មតាកន្ទួលលេចចេញឡើងនៅពេលប្រហែល 14 ថ្ងៃ ក្រោយពីឆ្លងមេរោគមក។

## តើអ្នកណាខ្លះដែលអាចមានគ្រោះថ្នាក់កើតជំងឺនេះ?

កញ្រ្ជឹលគឺជាជំងឺទូទៅមួយនៅមុនឆ្នាំ 1966 ដូច្នេះជនភាគច្រើនដែលមានកំណើតមុនឆ្នាំនោះមានប្រព័ន្ធការពារទប់ទល់នឹងរោគនេះ។

អ្នកមានគ្រោះថ្នាក់កើតកញ្ជ្រឹលមានរួមទាំង៖

- អ្នកមានកំណើតក្នុងអំឡុងឬចាប់ពីឆ្នាំ 1966 ដែលមិនធ្លាប់កើតកញ្ជ្រឹល ហើយដែលមិនបានចាក់ថ្នាំបង្ការរោគកញ្ជ្រឹល-សាទ្បាទែន-ស្អូច (MMR) ចំនួនពីរកំរិត ចាប់ពីអាយុ 12 ខែ។
- អ្នកមានប្រព័ន្ធការពារទប់ទល់រោគទន់ខ្សោយ (ឧទាហរណ៍៖ អ្នកកំពុងទទួលការព្យាបាលដោយវិធីគីមីឬដោយវិទ្យុសកម្មសំរាប់រោគមហារីក ឬអ្នកលេបថ្នាំស្តេរ៉ូអ៊ីដតាមកំរិតខ្ពស់) ទោះជាអ្នកទាំងនោះបានចាក់ថ្នាំបង្ការរោគពេញលេញ ឬធ្លាប់កើតកញ្ជ្រឹលកាលពីពេលកន្លងមកក៏ដោយ។
- អ្នកគ្មានប្រព័ន្ធការពារទប់ទល់នឹងរោគនេះ ហើយធ្វើដំណើរទៅបរទេស។

## តើវិធីបង្ការជំងឺនេះធ្វើឡើងដោយរបៀបណា?

- ការការពារប្រសើរបំផុតទល់នឹងកញ្ជ្រឹលគឺការចាក់ថ្នាំបង្ការរោគ MMR ចំនួនពីរកំរិត។ ថ្នាំបង្ការរោគនេះផ្តល់ការការពារមិនឲ្យឆ្លងរោគកញ្ជ្រឹល ព្រមទាំងរោគសាទ្បាទែន និងរោគស្អូច។
- ថ្នាំបង្ការរោគ MMR គួរចាក់ឲ្យកុមារនៅពេលមានអាយុ 12 ខែ ហើយកំរិតទីពីរគួរចាក់នៅពេលមានអាយុ 4 ឆ្នាំ។
- អ្នកដែលកើតក្នុងអំឡុងឬក្រោយឆ្នាំ 1966 និងអ្នកដែលមិនធ្លាប់កើតកញ្ជ្រឹលឬបានចាក់ថ្នាំបង្ការរោគ MMR គួរធ្វើឲ្យប្រាកដថា ខ្លួនបានចាក់ថ្នាំបង្ការរោគ MMR ចំនួនពីរកំរិត ដោយមានចន្លោះពេលដាច់ពីគ្នាយ៉ាងតិចក៏បួនអាទិត្យដែរ។
- ការចាក់ថ្នាំបង្ការរោគច្រើនជាងពីរដងមិនបង្កគ្រោះថ្នាក់អ្វីទេ ដូច្នេះអ្នកដែលមិនដឹងច្បាស់ប្រាកដគួរចាក់ថ្នាំបង្ការរោគនេះ។
- អ្នកកើតកញ្ជ្រឹលគួរស្នាក់នៅផ្ទះរហូតទាល់តែរោគនេះលែងឆ្លងតទៅទៀត (ពោលគឺរហូតទាល់តែក្រោយកន្ទួលបានចាប់ផ្តើមចំនួន 4 ថ្ងៃមកហើយ)
- ចំពោះអ្នកដែលមិនស៊ាំនឹងរោគនេះហើយបានប៉ះនឹងអ្នកកើតកញ្ជ្រឹលវិញ ជួនកាលអ្នកនោះនៅតែអាចបង្ការជំងឺនេះបានបើចាក់ថ្នាំបង្ការរោគ MMR នៅក្នុងអំឡុងពេលបីថ្ងៃក្រោយពីបានប៉ះពាល់នឹងមេរោគជំងឺនេះ ឬចាក់ថ្នាំ immunoglobulin ក្នុងរង្វង់ពេល 7 ថ្ងៃក្រោយពីបានប៉ះពាល់នឹងមេរោគជំងឺនេះមក។

## តើការវិនិច្ឆ័យរោគធ្វើទៅតាមរបៀបណា?

- មានការសង្ស័យអំពីការកើតកញ្ជ្រឹលនៅពេលដែលអ្នកណាមួយមានអារម្មណ៍មិនស្រួលខ្លួន ក្អក ហៀរសំបោរ ឬឈឺភ្នែក និងមានចេញកន្ទួលក្រោយពីគ្រុនក្តៅ។
- ដើម្បីបញ្ជាក់អំពីការមានរោគកញ្ជ្រឹលនេះ នៅពេលណាក៏ដោយឲ្យតែមានការសង្ស័យអំពីការកើតកញ្ជ្រឹល ការធ្វើតេស្តឈាមនិងសំណាកពីច្រមុះ បំពង់ក និងសំណាកទឹកនោមគួរតែអនុវត្តឡើង។ ការបញ្ជាក់អំពីការកើតមានរោគនេះមានសារសំខាន់ណាស់ ដោយសារតែទង្វើនេះអនុញ្ញាតឲ្យផ្នែកសុខភាពសាធារណៈធ្វើការតាមពិនិត្យជាបន្ទាន់ចំពោះអ្នកដែលមានគ្រោះថ្នាក់កើតកញ្ជ្រឹល។

## តើវិធីព្យាបាលជំងឺនេះធ្វើឡើងដោយរបៀបណា?

- ជាធម្មតាអ្នកកើតកញ្ជ្រឹលទទួលឱវាទឲ្យសំរាក ទទួលទានជាតិទឹកឲ្យបានច្រើន និងលេបថ្នាំប៉ារ៉ាសេតាម៉ុលដើម្បីព្យាបាលគ្រុនក្តៅ។ គ្មានវិធីព្យាបាលជាក់លាក់សំរាប់ជំងឺកញ្ជ្រឹលឡើយ។
- នៅពេលដែលមានអ្នកកើតកញ្ជ្រឹល ជាការសំខាន់ដែលអ្នកជំងឺនេះកុំចេញពីផ្ទះ ដើម្បីកាត់បន្ថយលទ្ធភាពនៃការចម្លងរោគនេះទៅអ្នកដទៃ។

## តើផ្នែកសុខភាពសាធារណៈមានវិធានការឆ្លើយតបអ្វីខ្លះ?

វេជ្ជបណ្ឌិត មន្ទីរពេទ្យ មន្ទីរពិសោធន៍ សាលារៀន និងមណ្ឌលថែទាំកុមារត្រូវរាយការណ៍ប្រាប់ករណីកញ្ជ្រឹលទៅកាន់ផ្នែកសុខភាពសាធារណៈ (Public Health Unit) ក្នុងតំបន់។ បុគ្គលិកផ្នែកសុខភាពសាធារណៈនឹងធ្វើសម្ភាសន៍វេជ្ជបណ្ឌិតនិង

អ្នកជំងឺ(ឬអ្នកថែទាំ) ដើម្បីឲ្យដឹងនូវរបៀបដែលជំងឺនេះបានកើតមានឡើង រកមើលដឹងអ្នកដទៃដែលមានគ្រោះថ្នាក់កើតជំងឺនេះ អនុវត្តវិធានការគ្រប់គ្រង (ដូចជាការចាក់ថ្នាំបង្ការរោគ និងការរឹតត្បិតលើការទៅសាលារៀនឬទៅកន្លែងធ្វើការ) និងផ្ដល់ឱវាទផ្សេងៗទៀត។

## ដើម្បីទទួលព័ត៌មានបន្ថែម

ប័ណ្ណព័ត៌មាន “កញ្រ្ជឹលៈ ព័ត៌មានសំរាប់អ្នកប៉ះពាល់មេរោគ” មានព័ត៌មានជាក់លាក់សំរាប់អ្នកដែលបានប៉ះពាល់វីរុសកញ្រ្ជឹល ហើយមាននៅតាមវ៉ិបសៃៈ

http://www.health.nsw.gov.au/resources/publichealth/infectious/diseases/measles_contact_factsheet_pdf.asp

**ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW**



**1300 066 055**

**www.health.nsw.gov.au**